## ព្រះរាជក្រម នស/រកម/០១៩៦/២២

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

## ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

**ប្រកាសអោយប្រើ**

ច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី ដែលរដ្ឋសភាបានអនុម័ត នាសម័យប្រជុំ
នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ

# ច្បាប់

## ស្តីពី

## ការបង្កើតក្រសួងកិច្ចការនារី

មាត្រា ១ : ត្រូវបានបង្កើតក្រសួងកិច្ចការនារី ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងកិច្ចការនារីមានសមត្ថកិច្ចដឹកនាំ និង គ្រប់គ្រងលើវិស័យកិច្ចការនារី នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងកិច្ចការនារី ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូបជានារី ដែលអាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងកិច្ចការនារី ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

* * *